**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** [illegible]

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់ វិទ្យាស្ថានកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក វិន សុជាតិ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៣
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## <u>សំរេច</u>

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះ **វិទ្យាស្ថានកម្ពុជា** **"Institute of Cambodia"** ហៅកាត់ជាភាសាខ្មែរថា "វ.ក" និងហៅជាភាសាអង់គ្លេសថា "I.C." ។ វិទ្យាស្ថាន

មានទីតាំងគោល ស្ថិតនៅអាគារលេខ ៣១៤ ផ្លូវជាតិលេខ ៥ ភូមិគោរដ្ឋាន ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ : វិទ្យាស្ថានកម្ពុជា ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៣ : វិទ្យាស្ថានកម្ពុជា ធ្វើការបណ្តុះបណ្តាលគឺ :

- បរិញ្ញាប័ត្ររង ដែលមានរយៈពេលសិក្សា យ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ជាមធ្យម
- បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សា យ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១៥០ ក្រេឌីត ជាមធ្យម ។

មាត្រា ៤ : វិទ្យាស្ថានកម្ពុជា មានមហាវិទ្យាល័យ :

១- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម

២- មហាវិទ្យាល័យ នីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

៣- មហាវិទ្យាល័យ បច្ចេកវិទ្យាព័ត៌មាន និង ភាសាបរទេស

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ក៏ដូចជាប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៥ : វិទ្យាស្ថានកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជន ត្រូវមាន ចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ថ្នាក់ទី ១២ នៃមធ្យមសិក្សា ចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺសញ្ញាប័ត្រដែលមានតំលៃស្មើ ។

វិទ្យាស្ថានកម្ពុជា ត្រូវគោរព តាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៧ : នាយក វិទ្យាស្ថានកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរនិងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនទាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជននិងកីឡាអោយ

បានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានកម្ពុជា និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួល សញ្ញាប័ត្របរិញ្ញារង ឬ បរិញ្ញា តាមកំរិតនិងឯកទេស ដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់អោយ ដោយវិទ្យាស្ថានកម្ពុជា ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណី វិទ្យាស្ថាននេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានកម្ពុជា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

មាត្រា ១០ : អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីមុខការ"
- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ